# វគ្គទី១

# សំបុកឥតបា

(បទកាកគតិ)

១- យប់យន់យាផដល់ រាត្រីធ្លាក់ខ្យល់
បន្សល់សន្សើម សន្សំដួងចិត្ត
ផ្តេកផ្តិតផ្តួចផ្តើម ដផ្ទក់ដផ្ទើម
ផ្សះផ្សើមជីវិត ។

២- ខ្ទមតូចល្អួចស្តាប់ សូរសៀផសាសព្ទ
ខ្សឹបប្រាប់ផផឹត ដំបូលប្រក់មេឃ
សង្វេគដេកគិត ដេកកើយគំនិត
រីផរឹតតស៊ូ ។

៣- យ៉ាប់យ៉ឺនយូរយារ ទន្ទេញទាមទារ
ពុះពារគំរូ ឆន្ទៈអ្នកក្រ
ត្រដរធាប់យូរ សង្ឃឹមជាត់ធូរ
ធ្លាក់គួរវាសនា ។

៤- **ឈើទាល ផ្តៅជុំ** ជម្រកដំរំ
ទ្រនំសុខា **ដើងព្រៃ** លៃលក
ជ្រៀតជ្រកកាយា **កំពង់ចាម** ចារ
ចំណារចំណង ។

៥- **ពូរិទ្ធិ មីនរ៉ុម** របរសុខុម
ផ្សែរផ្សំខំក្រង ប្តីរត់ម៉ូតូ
ញើសហូរដោកខ្នង ប្រពន្ធជួយផង
លក់ផ្សងតាមឡាន ។

៦- រំដួលប្រិមប្រិយ **ប៉ែតសិបប្រាំបី**
ហាងថ្មីថ្មៃប្រាណ អាពីងចង្រិត
ប្រឹងឥតស្រាកស្រាន្ត ចំណូលចូលបាន
សុខសាន្តគ្រួសារ ។

៧- **នារី** កូនស្រី ស្រស់ស្អាតប្រិមប្រិយ
លកលៃកិច្ចការ ថ្នាក់ទីដប់ពីរ
នារីប្តេជ្ញា កែប្រែវាសនា
ភ្លឺថ្លាជីវិត ។

៨- ទោះខ្លួនជាស្រី ទោះសែនក្រក្រី
ទោះបីងងឹត ទោះជួបជូរចត់
ទោះផ្អត់គំនិត ក៏ខំយោងយឹត
ចិត្តរឹតប្រឹងប្រែង ។

៩- **វិទ្យាល័យស្គន់** **នារី** អត់ធន់
រែកពុនដាក់ស្ពែង ព្រឹកទៅសាលា
សិក្សាចារចែង ពេលថ្ងៃតាក់តែង
ម្នាក់ឯងជួយម៉ែ ។

១០ - សម្រាលបន្ទុក ជួយដល់ម៉ែពុក
ទំនុកថ្នមថៃ គ្រួសារតូចពិត
ជីវិតអ្នកស្រែ ខ្វះខាតហូរហែ
ឥតល្ហែដុនដាប ។

១១ - ដួងចន្ទខ្ជិលរះ ពន្លឺខ្ជិលជះ
មានះឈ្នះបាប ស្បៃអន្ធការ
យាត្រាក្រាលក្រាប សន្ធឹងប្រឹងឆាប
កំណាព្យជីវិត ។

១២ - គ្រួសារក្រីក្រ    បីនាក់ត្រដរ
បន្តយោងយឺត    ព្រលឹមព្រលប់
ថ្ងៃយប់ងងឹត    នឿយហត់ខ្សត់ពិត
គេងគិតឥតឈប់ ។

១៣ - **នារី** កូនល្អ    ទៀបភ្លឺបន្ត
ចេញចរពីយប់    ជួយរៀបចំម្ដាយ
ដោះស្រាយសព្វគ្រប់    ចម្អិនលើសលប់
ជួយទប់ចំណាយ ។

១៤ - ព្រលឹមរូតរះ    **នារី** ជម្នះ
ចេញជះចាកឆ្ងាយ    សំដៅសាលា
សិក្សាត្រួសត្រាយ    ត្រឹមត្រូវចិត្តកាយ
សប្បាយសម្បូរ ។

១៥ - សិស្សល្អតស៊ូ    **នារី** គិតគូរ
ស្ដាប់គ្រូហៃហូរ    យកចិត្តទុកដាក់
រៀនស្ម័គ្រផ្ដាច់ប្ដូរ    ទំនងទំនោរ
ជន់ដោរពូកែ ។

១៦ - លោកគ្រូ អ្នកគ្រូ        សរសើរជាយូរ
គិតគូរឥតល្ហែ        ដំរុញទឹកចិត្ត
ខំខិតឥតប្រែ        ឧបត្ថម្ភថៃ
ហូរហែសិក្សា ។

១៧ - ថ្ងៃមួយព្រួយដល់        **នារី** ខ្វាយខ្វល់
បន្សល់បញ្ហា        ថ្ងៃត្រង់គ្រោះថ្នាក់
ប្រវាក់ខ្មោចផ្សា        **ពូរិទ្ធិ** ទុក្ខា
ចរាចរណ៍ធំ ។

១៨ - សន្ទឹករថយន្ត        បំបោលលឿនលន់
ទម្ងន់ជួបជុំ        បុកម៉ូតូប្រាវ
ឈាមរ៉ាវច្រាលធំ        ទ្រនាប់ទ្រនំ
ស្រែកយំឈូឆរ ។

១៩ - លោកពូកម្សត់        កម្សោយដោយហត់
ដោយអត់មាត់ក        សន្ធប់ស្ដូកស្ដឹង
លែងដឹងខ្មោស        ប្រជាជនល្អ
បន្តខំជួយ ។

២០ - លើកដាក់ភ្លាមៗ រ៉ឺម៉កកកឈាម
គំរាមក្រៀមព្រួយ មន្ទីរពេទ្យស្រុក
សម្រុកជំនួយ ជីវិតពូមួយ
រញ្ជួយរំជួល ។

២១ - ដំណាលដំណឹង ផុះដាលប្រាលដឹង
តានតឹងខ្សឹកខ្សួល **មីងរ៉ុម នារី**
ញាំញីប្រែប្រួល ត្រូវរដើរដួល
កម្សួលទឹកភ្នែក ។

២២ - ទឹកភ្នំលោកីយ៍ ម្ដាយនិងកូនស្រី
សម្ដីយំយែក យ៉ាប់យុឺនដួងចិត្ត
លោហិតប្រៀកជ្រែក ទុក្ខាចារញែក
រំលែករំលាយ ។

២៣ - រំលំរំលត់ ខ្លោចផ្សារន្ធត់
ទ្រូងមុតផ្ទុះធ្លាយ ទុក្ខជាន់លើទុក្ខ
ជ្រុកទន់ជ្រាយ ទំនងទំនាយ
រាយមាយសោកា ។

២៤ - ក្រៀមក្រំក្រក្រី គ្មានទ្រព្យធនអ្វី
ជាក្តីមេត្តា សង្ឃឹមសំខាន់
ប្រកាន់ចិន្តា គ្រោះថ្នាក់ប្រហារ
វាសនាលោកពុក ។

២៥ - លោកពូរបួស ស្ទេកស្ទាំងស្ទុតហួស
ស្ទុតព្រោះគ្រោះទុក្ខ ទោះពេទ្យខំជួយ
ជំនួយគ្រប់មុខ ថ្នាំពេទ្យគំហុក
វាយលុកសង្គ្រោះ ។

២៦ - ក៏ជោគវាសនា **ពូរិទ្ធិ** ខ្លោចផ្សា
ទុក្ខាចារឆ្តោះ មច្ចុរាជប្រឹង
សម្ទឹងកត់ឈ្មោះ ជីវិតរង្គោះ
សាបព្រោះក្សិណក្ស័យ ។

២៧ - គួរឱ្យអាសូរ ទឹកភ្នែកស្រក់ហូរ
ជន់ជោរតម្លៃ ជាតិជាអ្នកក្រ
ត្រដរយប់ថ្ងៃ គ្រោះថ្នាក់ចង្រៃ
ប្រល័យជីវិត ។

២៨- បំបែកបំបាក់ សង្ខារចារធ្លាក់
ចម្ងាក់ងងឹត ស្លាប់ចោលគ្រួសារ
ខ្លោចផ្សាគេងគិត កូនប្រពន្ធពិត
រីងរឹតរីងរៃ ។

២៩- អាសូរ **នារី** ទុក្ខទួញមួលមីរ
វក់វីទុក្ខភ័យ បង្គោលគ្រួសារ
សង្ខារអស់ន័យ គ្រោះបរាជ័យ
ប្រល័យវាសនា ។

៣០- ពីថ្ងៃនេះទៅ ម៉ែនិងពាលពៅ
រស់នៅឯកា ពីរនាក់ម្ដាយកូន
ស្ងាត់សូន្យគេហា សំបុកឥតបា
ចំណារចំណង ។

៣១- ចំណូលចំណាយ ចំណែកដោះស្រាយ
ខ្វល់ខ្វាយកន្ទង ជួបជុំជួបជិត
ទុក្ខរឹតក្រៀកចង តើឱ្យនួនល្អង
គិតផ្សងយ៉ាងណា ?

# វគ្គទី២
# អំពែរគ្រួសារ

(បទពាក្យប្រាំពីរ)

៣២ - ផ្គរស្រែកក្ខូងៗ ទូងគ្រឹមៗ
ភ្លៀងយំរលឹម លាងលោកា
កង្កែបកូបៗ ស្រូបសោតា
ហូរទឹកនេត្រា ផ្សាលាក់លួច ។

៣៣ - ម៉ង់ៗ ម៉ក់ៗ ដក់ដានដឹង
**នារី** សម្ងឹង តាមបង្អួច
ស្រពាប់ស្រពោន កូនចិត្តក្ដួច
នឹកពុកព្រឺព្រួច ប្រាណឯកា ។

៣៤ - ធ្លាប់រស់ជួបជុំ ទ្រនំសុខ
តូចមែនសំបុក ស្រណុកថ្វា
សុភមង្គល យល់សុខា
មាតាបិតា សែនកក់ក្ដៅ ។

៣៥ - ធ្លាប់ស្ដាប់ពាក្យពុក ទុកជាក្បួន
រស់មិនសាបសូន្យ ចិត្តកូនចៅ
តម្រែតម្រង់ ផ្គង់គោលដៅ
អប់រំផុតខ្មៅ ហៅរៀនសូត្រ ។

៣៦ - ទោះបីក្រខ្សត់ អត់យ៉ាងណា
ក៏ពុកប្ដេជ្ញា ជួយរហូត
កាន់សុចរិត ជិតស្លូតបូត
ស្រស់ស្រាយស្រុះស្រួត ខំធ្វើការ ។

៣៧ - ពុកជាបិតា មហាល្អ
ទឹកចិត្តស្មោះសរ តមាតា
ឱ្យកូនខំរៀន មានប្រាជ្ញា
អនាគតថ្លា ចារជោគជ័យ ។

៣៨ - ពុកជាស្វាមី ប្រពៃណាស់
ការងារថ្មីចាស់ រហ័សរៃ
ជួយម៉ែថែកូន ក្បួនលកលៃ
រំដោះទុក្ខភ័យ នៃគ្រួសារ ។

៣៩ - ពុកជាបង្គោល យោលយ៉ាប់យ៉ឺន
រែកទុក្ខពាន់ម៉ឺន គ្រប់កិច្ចការ
ពលិកម្មស្មោះ ហួសវាចា
មិនគួរវាសនា សង្ខារខ្ចី ។

៤០ - គ្រោះថ្នាក់គ្រោះថ្នាល ដាលជិតដាម
ចរាចរណ៍តាម ស្នាមវិថី
ឃាតករមុខស្រស់ ហោះលោកីយ៍
ម្តេចមិនប្រណី សម្លាប់ពុក ។

៤១ - ឱ លោកមានឡាន ក្លាហានហោះ
ម្តេចមិនស្រណោះ អស់ទោសទុក្ខ
ទំនើបទំនង រងទំនុក
បំបោលផ្កាប់មុខ លុកសម្លាប់ ។

៤២ - សំឡេះសម្ទឹង ប្រឹងសម្ងក់
ចិត្តអ្នកអាក្រក់ ធក់ប្រញាប់
ច្បាប់ចរាចរណ៍ ក៏មិនត្រាប់
របួសនិងស្លាប់ មិនលស់ថ្ងៃ ។

៤៣ - **នារី** រៀបរាប់ ភ្លាប់ទឹកភ្នែក
យ៉ាប់យ៉ឺនយំយែក ជ្រែកប្រល័យ
ប្រឡេះពុកទៅ នៅស្រមៃ
ស្រមោលចង្រៃ តាមយាយី ។

៤៤ - អាណិតអាណោច ខ្លោចប្រមាត់
ប្រមើលវិបត្តិ ស្កាត់គ្រប់ទី
ពុកទៅម៉ែនៅ ត្រូវញាំញី
ម៉ែកូនទាំងពីរ រីវង្វេង ។

៤៥ - អំរែកគ្រួសារ មហាធ្ងន់
ពុះពាររែកពុន ធន់ជំពេង
ក្រទ្រព្យអក័ព្វ ជាប់សង្រេង
បំណុលស្ពាំឆ្វេង កេងកុះករ ។

៤៦ - ម៉ែខិតម៉ែខំ សមធួរធារ
លំបាកវេទនា ជាបន្ត
លក់ដូរលែងដាច់ ផ្កាច់ត្រដរ
ជួនហុតបបរ ទ្រទ្រាំស៊ូ ។

៤៧ - **នារី** វីវក់ ទក់ដោយទុក្ខ
បាត់បង់លោកពុក មុខឡើងជូរ
រៀនផងរកផង ចង់គិរូ
ធ្វើការគិតគូរ បណ្ណាគារ ។

៤៨ - ព្រឹករៀនគ្មានឈប់ ថ្ងៃធ្វើការ
ហាងមុខសាលា ទៀងវេលា
**ហាងចំណេះពិត** គិតពុំផា
ចំណូលផ្សំគ្នា ជួយអ្នកម្ដាយ ។

៤៩ - ម្ចាស់ហាងអាណិត ត្បិត **នារី**
ឧស្សាហ៍វក់វី ទីជិតឆ្ងាយ
ចំណេះចំណាប់ ចាប់ចំណាយ
ចំណូលចែកចាយ ស្រាយស្មោះត្រង់ ។

៥០ - ប្រាក់ខែបាយទឹក ព្រឹកល្ងាចយប់
ផ្គត់ផ្គង់សព្វគ្រប់ ទប់ផ្ចិតផ្ចង់
ផ្ទុងផ្ដើមផ្សើមគិត រឹតតម្រង់
គោលដៅចំណង់ ចង់ធ្វើគ្រូ ។

៥១ - បានប្រាក់ដាក់ចិត្ត គិតសន្សំ
បំណុលនាងខ្ញុំ ដោះធាប់យូរ
សល់ប្រាក់តិចតួច លួចគិតគូរ
ម៉ែកូនតស៊ូ ចិញ្ចឹមប្រាណ ។

៥២ - ឱ ខ្សែជីវិត ពិតលំបាក
តែមិនអាចផ្អាក ចាករំខាន
**នារី** ខិតខំ សមចំណាន
សង្ឃឹមនឹងបាន សុខសាន្តធូរ ។

៥៣ - ទោះបីក្រីក្រ ក៏ **នារី**
រៀនបានគ្រប់ទី វីរក់ស៊ូ
ហាត់ពត់លត់ដំ ខំធាប់យូរ
វីរៈគំរូ សិស្សពូកែ ។

៥៤ - ប្រឡងបាក់ឌុប យប់ថ្ងៃរៀន
វិជ្ជាជាស្ពាន យានស្និទ្ធស្នេហ៍
អំរែកគ្រួសារ ហាត់ហួរហែ
**នារី** នៅតែ ថែសិក្សា ។

៥៥ - សង្ឃឹមចិត្តស្ម័ គិតគូរជួយ
ចំណោះជំនួយ ស្ងួយប្ដេជ្ញា
បានដូចបំណង ប៉ងប្រាថ្នា
សម្រេចវាសនា **នារី** ស្រី ។

ចិត្តជានារី

## វគ្គទី៣
# ទុក្ខាកំព្រា

(បទព្រហ្មគីតិ)

៥៦ - ជីវិត រីតតស៊ូ
គន់គិតគួរ ប្រក្រតី
ខិតខំ ចំវិថី
ខ្នឹតឃ្នាតខ្មី លៃលកប្រឹង ។

៥៧ - ណាមួយ ព្រួយសិក្សា
ផ្ដាំប្ដេជ្ញា ចារដំណឹង
បាក់ឱប គ្រប់ប្រាណដឹង
ប្រឡងតឹង ប្ដឹងចំណោះ ។

៥៨ - រៀនហើយ ធ្វើយរៀនទៀត
ធ្មៀតអើយធ្មៀត ឃ្វាតប្រហែស
វិសាល ប្រាលវិសេស
រៀនឱ្យចេះ យល់ចាំជាក់ ។

៥៩ - **នារី** រីរក់រិល
រៀនមិនខ្ជិល មិនស្មើរស្មាក់
ជួបជុំ ជិតមិត្តភក្តិ
ចង់ជាផ្អាក់ ក្បឹបសិក្សា ។

៦០ - ជួយគ្នា ជាទម្លាប់
ញយញឹកញាប់ ជាប់កាយា
ព្រឹករៀន ថ្ងៃធ្វើការ
សង្ឃឹមថា ដូចបំណង ។

៦១ - ថ្ងៃខែ ឆ្នាំរឹតកៀក
បន្ទុកក្រៀក រឹតតែចង
ទម្ងន់ ធ្ងន់កន្ទង
ឱ្យទួនល្អង ផ្សងដោះស្រាយ ។

៦២ - មាតា ផ្សាចុកឈឺ
រោគជំងឺ ព្រឺព្រួចកាយ
ចុកចាប់ យ៉ាប់នឿយណាយ
អាសូរម្ដាយ ដេកលើគ្រែ ។

៦៣ - ស្គមស្គាំង ទាំងសម្រស់
សែនស្រណោះ ហោះប្រួលប្រែ
រូបឆោម ទ្រោមបង្វែរ
នាងខំថែ តែមិនធូរ ។
៦៤ - ថ្នាំពេទ្យ ឆ្អែតឆ្អន់ដោក
ព្យាបាលរោគ អស់ជាយូរ
ប្រាក់កាស ជះគិតគូរ
ញាតិមិត្តគ្រូ ស៊ូជួយជាប់ ។
៦៥ - នៅតែ មិនអាចជួយ
ជីវិតមួយ ព្រួយអក័ព្វ
**មីងរ៉ុម** សុំញឹកញាប់
កូនកាន់ខ្ជាប់ ទ្រព្យវិជ្ជា ។
៦៦ - ម៉ែផ្តាំ ចាំណាកូន
ម៉ែនឹងសូន្យ ចោលពុំងា
ជីវិត ពិតមិនធារ
ដោយរោគា តាមយាយី ។

៦៧ - កើតចាស់ ឈឺហើយស្លាប់
នេះជាច្បាប់ គ្រប់ទិសទី
កុំយំ ណា **នារី**
សូមជីវី ខំតស៊ូ ។

៦៨ - ពេលអត់ ពីម៉ែទៅ
សូមពាលពៅ នៅគិតគូរ
បំណង ប៉ងធ្វើគ្រូ
ជាគំរូ ផ្គងខ្នងជាតិ ។

៦៩ - សូមកូន ប្រឹងប្រែងរៀន
យករបៀន ប្រៀនមិត្តញាតិ
បាក់ឱប គ្រប់កុំឃ្លាត
សូមកូនផ្ទៀត យកឱ្យបាន ។

៧០ - សិក្សា ក្លាខ្ជឹមខ្លាំង
ជាកម្លាំង ច្បាំងចិត្តប្រាណ
ចំណេះ ចេះចំណាន
រស់សុខសាន្ត ស្រាន្តស្រស់ស្រាយ ។

៧១ -  កង្វល់ ខ្វល់ខ្វាយពេញ
ទុក្ខទន្ទេញ វេញចំណាយ
ចាក់ស្រោប ក្តោបចិត្តកាយ
**នារី** ក្លាយ ក្រៀមភក្ត្រា ។

៧២ -  ទោះក្រ ក៏តស៊ូ
នាងគិតគូរ យកមាតា
ទៅពេទ្យ យល់ហេតុការណ៍
ពេទ្យប្រាប់ថា ហួសពេលហើយ ។

៧៣ -  ជំងឺ ឈឺរ៉ាំរ៉ៃ
មិនអាចថ្នែ ជួយបានឡើយ
ទឹកភ្នែក ជ្រែកឥតស្បើយ
ហូរឆ្ងងឆ្ងើយ កើយកៀកកិត ។

៧៤ -  **មីងរ៉ុម** ដ៏កម្សត់
នឿយណាយហត់ ខ្សត់ដាមដិត
ញើសហូរ ជោរលោហិត
ព្រហ្មលិខិត ឥតមេត្តា ។

៧៥ - ឆាបឆក់ ហក់ហើបហោ
ហោះសំដៅ ភពឯកា
មច្ចុរាជសង្ហារ
ចាប់ប្រហារ ជីវិតសូន្យ ។

៧៦ - បន្សល់ សំណល់ទុក្ខ
ធ្លាក់ថ្មើមក្ដុក ដល់រូបកូន
ពុកម៉ែ ថៃជាក្បូន
ចង់សណ្ដូន ជូនដល់ត្រើយ ។

៧៧ - ឥឡូវ ត្រូវកំព្រា
ម៉ែសូមលា ចោលកូនហើយ
ទុក្ខា ចារឥតស្បើយ
រកចម្លើយ ឆ្លើយមិនបាន ។

៧៨ - ធ្លាប់ឱប ក្រសោបកាយ
ពីរនាក់ម្ដាយ កក់ក្ដៅប្រាណ
ជីវិត ពិតសុខសាន្ត
ម៉ែរុញប្រាន កូនរឹងមាំ ។

៧៩- ធ្លាប់ស្តាប់ សព្ទទូន្មាន
ពាក្យម៉ែប្រៀន ស្ពានជោកជាំ
ជោគជ័យ លៃលកទ្រាំ
ពិតពាំនាំ កូនខ្ពង់ខ្ពស់ ។

៨០- ធ្លាប់ហែល ក្រៃលក្រាស់ក្រៃ
ទុក្ខយប់ថ្ងៃ ថ្នៃសង្គ្រោះ
សង្ឃឹម ត្រឹមបានរស់
កិត្តិយស ផ្គោះសុខា ។

៨១- ម៉ែអើយ ឱអ្នកម៉ែ
ថ្នាក់ថ្នមថៃ កែវាសនា
កូនរស់ ព្រោះមាតា
ជួយរក្សា ស្នេហាពិត ។

៨២- ពេលអត់ ពីម៉ែទៅ
ជីវិតពៅ ត្រូវផងផឹត
តែលតោល ជោលជួបជិត
ទុក្ខរួមរឹត រស់រឹងរៃ ។

៨៣ - បណ្តាំ ផ្តាំប៉ុន្មាន
ពុកម៉ែបាន ប្រានលកលៃ
រស់ភ្ជាប់ អត្ថន័យ
ជួយជោគជ័យ ថ្ងៃខាងមុខ ។

៨៤ - ទោះកូន ខ្លួនជាស្រី
ម្នាក់ឯងក្តី ក៏ភ្នំទុក្ខ
កំព្រា ទារវាយលុក
មិនអាចផ្ទុក ឃាត់រំខាន ។

៨៥ - កូននឹង ប្រឹងបន្ត
គោលដៅល្អ កសាងប្រាណ
សម្រេច ស្រេចដើមដាន
សែនសុខសាន្ត បានសមសួន ។

## វគ្គទី៤

# ជោគជ័យសិក្សា

(បទបន្ទោលកាក)

៨៦ - បន្ទាប់ ពីម្ដាយ
បានចាកចេញឆ្ងាយ ពីខ្លួន
**នារី** មាំមួន
ពង្រឹងផ្ទួនៗ ខិតខំ ។

៨៧ - សិក្សា ការងារ
ប្រឹងប្រែងពុះពារ សក្តិសម
ស្ដីស្ដាប់ ស្ដុកស្ដម្ភ
ខ្លាំងក្លាខ្លឹមក្លំ ហំហាន ។

៨៨ - ទោះនៅ សាលា
ស្ដាប់គ្រូអាចារ្យ ចំណាន
ចំណេះ ជាប់ប្រាណ
**នារី** ចាប់បាន ពូកែ ។

៨៩- ទោះធ្វើ ការងារ
វែកពុនពុះពារ ហូរហែ
ឧស្សាហ៍ មិនប្រែ
ផ្គាប់ចិត្តឥតល្ហែ គ្មានទាស់ ។

៩០- ទំនង ទំនេរ
មាំមួនមាសមេ កាយគាស់
សៀវភៅ ជាឃ្នាស់
វិជ្ជាលូតលាស់ លើសលប់ ។

៩១- បាក់ឌុប មកដល់
សមិទ្ធផល សព្វគ្រប់
កើតកើន ជាម្ចប់
ខំរៀនមិនឈប់ កើនទ្វេ ។

៩២- **នារី** គិតប៉ង
ប្រឹងប្រែងប្រឡង សំណេរ
គ្រប់មុខ វិះវេ
បានល្អជាងគេ អស្ចារ្យ ។

៩៣ - ប្រកាស ប្រឡង
លទ្ធផលប៉ង សិក្សា
រំភើប ចិន្តា
បាន **និទ្ទេសអា** ដូចចិត្ត ។
៩៤ - ទឹកភ្នែក សប្បាយ
ផ្ដើមស្រក់បែកចាយ ដាមដិត
កម្លាំង ខំខិត
ញើសឈាមលោហិត តស៊ូ ។
៩៥ - មិត្តភក្តិ ញាតិមិត្ត
អបអរជុំជិត គិតគូរ
លោកគ្រូ អ្នកគ្រូ
លើកជាគំរូ បន្ត ។
៩៦ - សប្បុរសជន
លើសលប់លើសលន់ កុះករ
រង្វាន់ អ៊ូអរ
ជួយដល់សិស្សល្អ ហូរហែ ។

៩៧ - កម្លាំង ទឹកចិត្ត
សន្ទឹងសណ្ឋិត ឥតប្រែ
**នារី** ពូកែ
ព្យាយាមឥតល្ហែ ថៃថ្ងូន ។

៩៨ - ចាត់ចែង ចិន្តា
រៀបចំឯកសារ ផ្ទាល់ខ្លួន
ដាក់ពាក្យ សមសួន
សុបិនមាំមួន ប្រឡង ។

៩៩ - គរុកោសល្យ
កំពង់ចាមផ្តល់ ចំណង
ដួងចិត្តចាំចង
គ្រូបង្រៀនផ្សង មាគ៌ា ។

១០០ - កម្រិត មូលដ្ឋាន
ចំណេះចំណាន វេលា
**គណិតវិទ្យា**
សង្ឃឹមពុះពារ បានជាប់ ។

១០១ - ទោះបេក្ខជន
លើសលប់លើសលន់ ទម្លាប់
តែមិន អភ័ព្វ
**នារី** ល្អគាប់ ខិតខំ ។
១០២ - ជួបជួន ជោគជ័យ
ពូកែឈ្លាសវៃ ស្ទុកស្តម្ភ
ល្បីល្បាញ ឧត្តម
**នារី** សក្តិសម គ្រូល្អ ។
១០៣ - សេចក្តី សង្ឃឹម
រីករះញញឹម បន្ត
ទំហំ ត្រេកអរ
កកកុញកុះករ ក្រាស់ក្រៃ ។
១០៤ - ទោះជា **នារី**
ទុក្ខទួញញាំញី យប់ថ្ងៃ
ទោះក្រ ក៏ថ្លៃ
សាធគុណតម្លៃ ថ្ងៃថ្លា ។

១០៥- អ្នកបេះ គឺជាប់
មានវាសនាភ័ព្វ សិក្សា
ធនធាន បញ្ញា
អភិវឌ្ឍស្មារ សង្គម ។

១០៦- កម្លាំង តស៊ូ
គម្រោងគំរូ សែនធំ
ទ្រនាប់ ទ្រនំ
ជួបជិតជួបជុំ សុខសាន្ត ។

១០៧- ប្រៀបដូច **នារី**
គ្រប់ទិនគ្រប់ទី រំខាន
តស៊ូ ចិត្តប្រាណ
លុះសម្រេចបាន សុខា ។

ស៊ុនិត

## វគ្គទី៩

# ស្នេហាគ្រាំគ្រា

(បទបថ្យាវដ្ត)

១០៨- **នារី** សោកី សោក័ណាគាប់ចិត្ត
ព្យាយាមខំខិត ដាមជិតសិក្សា
ប្រឡងជាប់គ្រូ គំរូថ្លៃថ្លា
ចាកឆ្ងាយគេហា ស្រវាវិជ្ជា ។

១០៩- ឱ ស្រុកកំណើត បង្កើតជន្មា
ឥឡូវឃ្លាតឃ្លា ពុំងាលាហើយ
លាខ្ទមកម្សត់ គេងកត់កៀកកើយ
ចាបយំឆ្លងឆ្លើយ ល្ហែល្ហើយចិន្តា ។

១១០- លាបងប្អូនមិត្ត ធ្លាប់យកអាសារ
គ្រូបាអាចារ្យ ធ្លាប់បានទូន្មាន
សាលារៀនល្អ កសាងធនធាន
ម្ចាស់ហាងជាស្ពាន ជាយានឈានឆ្លង ។

១១១ - គរុកោសល្យ ផ្ដល់ដូចបំណង
**កំពង់ចាម** ចង ផ្សងកិច្ចសិក្សា
**នារី** ជ្រៀតជ្រែក ជម្រកអាត្មា
ស្នាក់ក្នុងសាលា ប្រាថ្នាសន្សំ ។
១១២ - សំបែប្រាក់កាស ដេរដាសរៀបចំ
អន្ទេសក្ដិសម ស្ដុកស្ដម្ភធនធាន
ទឹកភ្លើងប្រើប្រាស់ រហ័សជំហាន
បណ្ដុះឱ្យមាន សុខភាពល្អ ។
១១៣ - ជម្រកជំរំ ទ្រទំបវរ
មូលមិត្តកុះករ កំដរជាគ្នា
ប្អូនខេត្តជួបជិត ជួបមិត្តគ្រប់គ្រា
ជីវិតកំព្រា ប្រែជាកក់ក្ដៅ ។
១១៤ - **នារី** តស៊ូ គិតគូរគោលដៅ
សុបិនពោមពៅ ជិតបានដល់ត្រើយ
ឆ្លៀតពេលទំនេរ រិះរេផតស្បើយ
ស្វ័យសិក្សាឆ្លើយ ចម្លើយគុណវុឌ្ឍិ ។

១១៥ - បច្ចេកវិទ្យា ភាសាមោះមុត
មាំអនាគត ប្រយុទ្ធល្ងង់ខ្លៅ
ព្រលប់រាត្រី លកលៃសំដៅ
បង្រៀនគួរក្រៅ កូនចៅក្មេងៗ ។

១១៦ - ប្រសប់ប្រសើរ ប្រើប្រាស់សំឡេង
ឈ្លាសវៃស្ដាំឆ្វេង ចិញ្ចឹមកាយា
ខ្លួនទីពឹងខ្លួន មាំមួនចិន្ដា
កែប្រែវាសនា ថ្ងៃថ្វាថ្កើងថ្កាន ។

១១៧ - រៀនបានមួយឆ្នាំ សកម្មចិត្តប្រាណ
**នារី** ក៏បាន ស្រាកស្រាន្តស្រស់ស្រាយ
សម្រស់ស្រស់ស្អាត សង្ហាតឆើតឆាយ
ដូចបុប្ផាផ្សាយ ក្លែបក្លិនគន្ធា ។

១១៨ - វ័យដប់ប្រាំបី ស្រស់ស្រីសោភា
សោភ័ណហូរហៀរ វេលាពេញវ័យ
កំលោះៗ ស្រណោះលកលៃ
ជួបជូនជោគជ័យ ចង់បានជាគូ ។

១១៩ - ពន្ទកស្នេហ៍ពិត និស្សិតស្នេហ៍គ្រូ
ផុះដាលក្រាលស៊ូ គំរូបចងចារ
កំលោះ **ធារិទ្ធិ** និស្សិតសង្ហា
រៀនបរិញ្ញា **សាលាហុងគ្រី** ។

១២០ - ជំនាញពេទ្យសត្វ ស្កាត់ជួប **នារី**
បេតីពេញទី រក់រីវង្វេង
កំណើតស្នេហា ចារចេញពីក្មេង
បង្អាប់លេងៗ ពេលនាងបង្រៀន ។

១២១ - នារីជាគ្រូ បង្រៀន **សុខមាន**
ដែលជាជំហាន ឈានទៅស្និទ្ធស្នាល
បណ្ដាញបណ្ដុះ ស្រូតស្រុះបណ្ដាល
ប្អូនស្រីលៃក្រាល ថ្នាលស្នេហ៍ជូនបង ។

១២២ - **សុខមាន** ប៉ូកប៉ែវ ជួយនាំសារផង
ចំណោញចំណង ស្នេហ៍ស្នងស្នេហ៍ស្និទ្ធ
សាងអនុស្សា ស្នេហាចារជិត
ស្រឡាញ់ពេញចិត្ត អាណិត **នារី** ។

១២៣ - **ស្ពានតីហ្សូណា** ថ្នាលស្នេហ៍ទាំងពីរ
លម្ហែជីវី គយគន់គង្គា
**កោះប៉ែន ជីផុះ** ដុតពោតជុំគ្នា
**ភ្នំប្រុសស្រី** ជា សាក្សីស្នេហ៍ស្មោះ ។

១២៤ - **នគរបាជ័យ** លកលៃអាឡោះ
សាច់អាំងស្រណោះ **ហាងម្ហូបឫស្សី**
ភ្លើងស្នេហ៍ដុតរោល កញ្ជ្រោលវិថី
សង្ឃឹមអ្វីៗ ដូចក្តីប្រាថ្នា ។

១២៥ - ស្នេហ៍យុវវ័យ ប្រពៃថ្លៃថ្លា
ស្រឡាញ់ប៉ុណ្ណា មេត្តាគោរព
ចេះឱ្យតម្លៃ គ្រាស់ក្រៃថ្លៃយប់
មិនបំពានម្ហូប់ គ្រប់ប្រពៃណី ។

១២៦ - **កំពង់ចាម** ចារ ស្នេហាទាំងពីរ
**ធារិទ្ធិ នារី** ស្នេហាប្រពៃ
បានត្រឹមប្រាំខែ ស្រាប់តែទុក្ខភ័យ
ជួបបរាជ័យ អស់ន័យគ្រាំគ្រា ។

១២៧ - ស្នេហ៍អ្នកទាំងពីរ ដល់ទីឃ្លាតឃ្លា
ទន្ទេញទាមទារ វេលាបំបែក
មាតាបិតា ចំណារចំណែក
វណ្ណៈខណ្ឌចែក រហែកដួងចិត្ត ។

១២៨ - ពុកម៉ែ **ធារិទ្ធិ** គេផ្គិតសណ្ឋិត
រើសអើងឡើងស្អិត ក្រៀមស្វិតវណ្ណៈ
មើលងាយ **នារី** គ្មានទ្រព្យគ្រប្រាក់
កំព្រាលើកដាក់ ឧបសគ្គស្នេហ៍ ។

១២៩ - ទោះមានអាជីព ជាគ្រូពូកែ
សង្ឃឹមប្រាក់ខែ បានតែមួយរស់
មិនអាចលើកស្ទួយ ជួយកូនឱ្យខ្ពស់
មានកិត្តិយស កេរ្តិ៍ឈ្មោះសុសសាយ ។

១៣០ - ហេតុនេះ **ធារិទ្ធិ** សូមគិតវែងឆ្ងាយ
សូមកូនតាមម្ដាយ រៀបការគូថ្មី
គេកូនអ្នកមាន ជាយានវិថី
ពុកម៉ែសេដ្ឋី លកលៃលក់មាស ។

១៣១ - ស្នេហ៍ភ្លើងចំបើង សូមប៉ើងវិនាស
កុំស្នេហ៍កូនរាស្ត្រ នាំមានទុក្ខា
**ធារិទ្ធិ** វិលវល់ ខ្វល់ក្នុងចិន្តា
ម្ចាស់ជាស្នេហា មេត្តាពេញចិត្ត ។

១៣២ - ម្ចាស់អ្នកមានគុណ លើសលន់ខំខិត
សាច់ឈាមលោហិត ជួយគិតកិច្ចការ
បើបងតាមម្ដាយ សែនស្ដាយជីវ៉ា
គ្រាំគ្រាយ៉ាងណា ស្នេហាស្មោះពិត ។

១៣៣ - កំពុងស្រឡាញ់ ក្ដក់ក្ដាញ់គួរគិត
បើបែកវរមិត្រ ខូចចិត្តពេកពន់
បើបងយកស្នេហ៍ មុខតែទម្ងន់
ឃាតអ្នកមានគុណ ទុក្ខធ្ងន់កើនទ្វេ ។

១៣៤ - អំរែកចំណង ចង់ចែកស្រែកជេរ
**ធារិទ្ធិ** រិះរេ តាមម្ដាយរៀបការ
បំផ្លាញដួងចិត្ត ស្នេហ៍ស្និទ្ធប្រេះឆា
ប្រាណឈឺក្រៃណា ពើតផ្សាគ្រាំគ្រា ។

១៣៥- បានត្រឹមឱបបង ចំណងកម្មពៀរ
ស្ពានស្នេហ៍ក្លាយជា ស្ពានបំបែកស្នេហ៍
ទឹកភ្នែកជួបជុំ យំយែកប្រួលប្រែ
រាប់អានត្រឹមតែ ជាមិត្តតទៅ ។

១៣៦- សំឡេងភ្លេងការ ប្រហារពាលពៅ
កំណាចឃោរឃៅ ឃុំឃាំងមង្គល
ឱ្យអូននៅរស់ រងគ្រោះវិលវល់
ងងឹតងងល់ យល់តែទឹកភ្នែក ។

១៣៧- ឱ ខ្សែជីវិត ស្នេហ៍ពិតរឹតជ្រែក
ប្រកាន់ខណ្ឌញែក នៅរាំងវណ្ណៈ
អ្នកមានអ្នកក្រ តឧបសគ្គ
ម៉ែទុកពុកដាក់ ប្រវាក់ទុក្ខា ។

១៣៨- ជាកូនកំព្រា វេទនាវាសនា
សង្ឃឹមភ្លឺថ្លា ស្នេហាជោគជ័យ
បែរជារងគ្រោះ របួសទុក្ខភ័យ
ស្នេហ៍សុខប្រពៃ អស់ន័យឃ្លាតឃ្លា ។

១៣៩ - **នារី** ជូនពរ បវរសោភា
គូស្នេហ៍យូរយារ វេលាសុខសាន្ត
សុភមង្គល ឥតយល់រំខាន
អូនស៊ូគ្រាំប្រាណ ចុកចាប់ម្នាក់ឯង ។
១៤០ - ស្នាមស្នេហ៍កម្សត់ សូមកត់តាក់តែង
រឿងស្នេហ៍ចំបែង ថ្លែងប្រាប់លោកីយ៍
សង្ឃឹមជាតិក្រោយ ឱ្យជួបវិថី
ស្នេហ៍ស្មោះភក្តី ឥតបីបែកបាក់ ។
១៤១ - ស្នេហ៍ពិតស្នេហ៍ពៅ ត្រូវផុតវណ្ណៈ
គ្រោះឧបសគ្គ សូមលាលុះក្ស័យ
ស្នេហ៍ស្និទ្ធស្នេហ៍ស្នង អូនបងថ្វាថ្លៃ
សាងគុណតម្លៃ គ្រាស់ក្រៃជានិច្ច ។

ខ្មែរ

# វគ្គទី៦

# គូព្រេងជួបគ្នា

(បទពាក្យប្រាំបី)

១៤២ - បញ្ចប់ការសិក្សា ថ្នាលអប់រំ
ពីរឆ្នាំជិតជួបជុំ ធំមិនភ្លេច
អនុស្សាវរីយ៍ ទីរំលេច
រំលឹករាល់ពាក្យពេចន៍ ចិត្តចងចាំ ។

១៤៣ - បានទ្រនំទ្រនាប់ ជាប់អាល័យ
កសាងគុណតម្លៃ ថ្ងៃយូរឆ្នាំ
ជួយបណ្តុះបណ្តាល ថ្នាលសកម្ម
គ្រូឧទ្ទេសផ្តែផ្តាំ បណ្តាំល្អ ។

១៤៤ - មិត្តភក្តិរួមជំនាន់ ទាន់តែងជួយ
ជំនុំជុំជំនួយ ស្ទួយកុះករ
បួនខេត្តស្ម័គ្រមេត្រី ស្តីអ៊ូអរ
សិក្សាឆើតឈូឆរ តវិជ្ជា ។

១៤៥ - នាមជាគរុសិស្ស ឫសអប់រំ
ឆ្អឹងខ្នងនៃសង្គម ជុំគ្រប់គ្នា
**នារី** រឹតតស៊ូ គួរយូរយារ
ហ្វឹកហាត់សម្បទា ជានាខ្លាំង ។

១៤៦ - ឆ្នាំសិក្សាថ្មោងថ្មី លកលៃប្រឹង
ចាប់ប៉ុស្តិ៍ស្រុះសម្ទឹង ដឹងកម្លាំង
បង្រៀនវិទ្យាល័យ ច្នៃតតាំង
ជំហានឈានប្រណាំង សែនល្អឆើត ។

១៤៧ - **នារី** ជាប់លេខមួយ ព្រួយខ្វាយខ្វល់
ចង់ត្រឡប់ទៅដល់ ស្រុកកំណើត
ជួយបង្រៀនអប់រំ ទ្រនំខ្នើត
**ស្រុកដើងព្រៃ** បង្កើត អើតគ្រប់គ្រា ។

១៤៨ - ចំណេះចេះចំណាន បានចំណាំ
**នារី** សិស្សសកម្ម ផ្ដាំគ្រប់គ្នា
ចាប់ប៉ុស្តិ៍បានដូចចិត្ត ជិតវេលា
**វិទ្យាល័យស្គន់** ជា ស្ពានចម្លង ។

១៤៩ - សាលារៀនគំរូ តស៊ូខំ
**នារី** ជ្រើសរើសចំ សមបំណង
សាលាធ្លាប់បានរៀន ប្រៀនហែលធ្លង
មកបង្រៀនសិស្សម្តង សងគុណគ្រូ ។

១៥០ - លោកគ្រូនិងអ្នកគ្រូ គំរូល្អ
ទទួលស្រួលបន្ត ក៏គិតគួរ
ជួយអបអរសាទរ ជំហរស៊ូ
សរសើរសិស្សធ្លាប់យូរ បានជោគជ័យ ។

១៥១ - ជាធនជានមនុស្ស ស្ទុះស្ទាស្ទាត់
ខំបង្រៀនទៀងទាត់ មិនភ្លាត់ន័យ
អប់រំក្មេងបន្ត ល្អប្រពៃ
រំដោះសិស្សផុតភ័យ មានបញ្ញា ។

១៥២ - ថ្ងៃចន្ទដល់ថ្ងៃសុក្រ នាងបង្រៀន
អប់រំខំទូន្មាន នៅសាលា
ថ្ងៃសៅរ៍និងអាទិត្យ គិតកិច្ចការ
បន្តការសិក្សា នៅសាកល ។

១៥៣ - សាកលវិទ្យាល័យ ច្នៃប្រឌិត
**វេស្ទើន** កើនគំនិត រឹតជួយផ្ដល់
ចំណេះចេះជំនាញ ទាញបន្សល់
បន្សាបរាល់ចម្ងល់ ខ្វល់សោយ ។
១៥៤ - កំណើតឆើតកំណាត់ កត់សំឡេង
សម្ញឹងមើលគូព្រេង ជួបជិតឆ្ងាយ
និស្សិតបរិញ្ញា ចារត្រួសត្រាយ
**ពិសិដ្ឋ** ចិត្តស្រស់ស្រាយ ក្លាយវិលវល់។
១៥៥ - របរគ្រូបង្រៀន គ្មានរើសអើង
តម្លៃថ្លៃថ្កុំថ្កើង ឡើងយោគយល់
ជាគ្រូបង្រៀនស្មោះ អស់អំពល់
មានសុភមង្គល គ្មានទុក្ខភ័យ ។
១៥៦ - បងគ្រូអូនក៏គ្រូ ស៊ូសិក្សា
សន្សំថវិកា ប្រាថ្នាជ័យ
**នារី** និង **ពិសិដ្ឋ** រឹតលក់លៃ
ស្រឡាញ់ស្មោះប្រពៃ ជាគូព្រេង ។

១៥៧ - រយៈពេលបួនឆ្នាំ ចាំចិត្តចង
សម្រេចនូវបំណង ប៉ងធំធេង
សាងនូវអនុស្សា ថ្នាលស្ដាំឆ្វេង
សញ្ញាបត្រគ្រូក្មេង បានបញ្ចប់ ។

១៥៨ - ភ្លេងការលាន់ទ្រហឹង ភ្លឹងពីរោះ
ប្រគំកិត្តិយស ឈ្មោះសំណព្វ
សំណាងអ្នកទាំងពីរ បានប្រសព្វ
ប្រសើរជួបកំណាប់ គូព្រេងព្រឹទ្ធ ។

១៥៩ - មានបងប្អូនញាតិមិត្ត ជិតជួបជុំ
ពរជ័យនៃសង្គម ធំពេកពិត
ដល់គូស្នេហ៍ថ្មោងថ្មី លៃគូរគិត
អស់ពេលមួយជីវិត រឹតស្មោះសរ ។

## វគ្គទី៧
# ចិត្តជានារី

(បទកាកគតិ)

១៦០ - អាពាហ៍ពិពាហ៍ ធំធាត់ធូរធារ
ទាមទារចិត្តល្អ ស្រឡាញ់អាណិត
យល់ចិត្តឈូធរ សកម្មកុះករ
បន្តបន្ទាប់ ។

១៦១ - អណ្តាតនិងធ្មេញ មិនអាចដោលដេញ
ជ្រក់ជ្រេញញឹកញាប់ ដូចប្តីប្រពន្ធ
អត់ធន់គុណគាប់ ទំនៀមទម្លាប់
ផ្សារភ្ជាប់សង្គម ។

១៦២ - ស្មោះត្រង់ភក្តី គ្រប់គូស្វាមី
ខន្តីជាធំ យោគយល់យូរយារ
ការងារជួបជុំ ជួយគ្នាអប់រំ
ទ្រនំគ្រួសារ ។

១៦៣ - **នារី ពិសិដ្ឋ** ស្នេហ៍ចិត្តនិងចិត្ត
ដាមជិតចិន្តា ការងារជាគ្រូ
តស៊ូខ្លាំងក្លា អភិវឌ្ឍស្តារ
ស្តង់ដាធនធាន ។

១៦៤ - ប្រាក់ខែថែថូន ពីរនាក់សមសួន
អង្រួនដូចស្ពាន សន្សៃសន្សំ
រៀបចំជំហាន ជំហរដូចយាន
ឥតមានទុក្ខា ។

១៦៥ - សុភមង្គល អត់ឱនយោគយល់
ឫសគល់សុខា ការងារតូចធំ
ជំនុំចរចា រួមសហការ
ប្តេជ្ញាដោះស្រាយ ។

១៦៦ - មិនចេះប្រចាំ សស្រាក់សស្រាំ
ចំណាំចំណាយ ចំណូលចំណេញ
បញ្ចេញចែកចាយ ស្រុះស្រួលស្រស់ស្រាយ
សប្បាយសម្បូរ ។

១៦៧ - បីឆ្នាំចាំដាប់ កើតកើនធនទ្រព្យ
ទម្លាប់ផ្លាស់ប្តូរ មានលុយមានឡាន
ចិត្តប្រាណចាប់ដោរ **ពិសិដ្ឋ** រឹតដូរ
ហៃហូរហ៊ឹហា ។

១៦៨ - ហ៊ឹកហ៊ាក់តាមហាង អំនួតអួតអាង
ប្រងាងកាយា មូលមិត្តមាំមួន
គេចពួនគ្រួសារ យប់ជ្រៅកាលណា
យាត្រាចូលផ្ទះ ។

១៦៩ - ផឹកស៊ីស៊ីផឹក ប្រមូលប្រមឹក
ក្លាយក្អឹករូតរះ ស្រីញីអូនបង
សាសង៍ជម្នះ ជំនឿជឿលះ
ប្រាក់ជះលើស្រី ។

១៧០ - ធ្វើបាបផ្លូវចិត្ត **នារី** ក្រៀមស្វិត
ដាមដិតសម្តី មាត់តូចមាត់ធំ
យែកយំព្រោះប្តី អាណិតប្រណី
ខន្តីបាត់សូន្យ ។

១៧១ - ចំណូលចំណាយ **ពិសិដ្ឋ** ចែកចាយ
សប្បាយនឹងអូន ចិញ្ចឹមស្រីញី
វក់វីសណ្ដូន សន្ដានបងប្អូន
តាដូនរិះគន់ ។

១៧២ - អាណិត **នារី** ខិតខំវក់វី
រកស៊ីស្រាលធ្ងន់ ប្រឹងប្រែងបង្រៀន
ជំហានវែកពុន ការងារលើសលន់
ក្រោយមុនពុះពារ ។

១៧៣ - មិនស្មានស្វាមី មិនស្មោះនឹងស្រី
ភក្ដីស្មារលោ លោភលន់លួចលាក់
ចិត្តភរិយា ទន្ទេញទាមទារ
ការងារគ្រប់យ៉ាង ។

១៧៤ - ទោះជាយ៉ាងណា **នារី** ប្ដេជ្ញា
ប្រាថ្នាសំណាង សំណោកជីវិត
ងងឹតប្រងាង ក៏នាងនៅអាង
ត្រដាងការពិត ។

១៧៥ - ចិត្តជា **នារី** តស៊ូមូលមីរ
វក់វីគេង៉គិត កែចរិយា
ចរចាជួបជិត ស្វាមីពិនិត្យ
គំនិតខ្លួនឯង ។

១៧៦ - បើបងព្រមកែ អូននៅតែថៃ
ចិត្តស្នេហ៍តាក់តែង កំហុសតូចធំ
ជួបជុំចំបែង លុបចេញជាក់ស្តែង
លែងថ្ងៃងវាចា ។

១៧៧ - ចិត្តអូននៅស្នេហ៍ ស្រឡាញ់មិនប្រែ
តែងតែមេត្តា អាណិតប្រណី
ស្វាមីក្រៃណា សង្ឃឹមរៀមរ៉ា
ថ្ងៃថ្វាដូចមុន ។

១៧៨ - តែបើប្រុសថ្ងៃ នៅតែចង្រៃ
យប់ថ្ងៃរែកពុន អបាយមុខ
ជង្រ្រុករិះគន់ ខុសរឹតតែធ្ងន់
ទោរទន់ទៅទៀត ។

១៧៩ - អូនក៏មិនទៅ កំណាចឃោរឃៅ
អាស្រូវមារយាទ ធ្វើបាបលើស្រី
ស្នេហ៍ប្ដីចោលម្សៀត បង្ខំវិវាទ
ឃៀវឃ្មាតពីច្បាប់ ។

១៨០ - ចិត្តជា **នារី** សុខចិត្តញាំញី
ជាទីសណ្ដាប់ សុំបែកផ្លូវគ្នា
ឃ្មាតឃ្មាប្រញាប់ លែងលះធាប់ៗ
ត្រងត្រាប់ត្រឹមត្រូវ ។

១៨១ - **ពិសិដ្ឋ** បានស្ដាប់ សូរសៀងសាសព្ទ
ឈឺចាប់អាស្រូវ ភ្ញោចភ្ញាក់រលឹក
ចាប់នឹកឃើញផ្លូវ តម្រង់តម្រូវ
ឆ្ពោះទៅសុខា ។

១៨២ - នាយឃើងចាប់យល់ សុភមង្គល
មានដល់គ្រួសារ ទម្ងន់ញឹកញយ
មួយរយកិច្ចការ ស្រីជាមាតា
ជួយស្ដារចម្ងង ។

១៨៣ - បុរសស្វាមី កើនល្បឿនល្បាញល្បី
ប្រពៃកន្ទង់ ព្រោះភរិយា
គ្រប់គ្រាវារច្ចង់ គិតគូរស្នេហ៍ស្នង
ចំណងចងចារ ។

១៨៤ - សោភ័ណ **នារី** សម្រស់ជីវី
គ្រប់ទីស្រស់ថ្វា សម្ដីនាំលាភ
សុភាពរាបសា សមចរិយា
ថ្ងៃថ្វាថ្ងៃថ្នូរ ។

១៨៥ - អ្នកធ្វើតែងខុស តែងមានកំហុស
ខាត់ដុសហែហួរ បេះខុសបេះកែ
តែងតែផ្លាស់ប្ដូរ ដេញដោលដោះដូរ
ទន់ទោររកត្រូវ ។

១៨៦ - **ពិសិដ្ឋ នារី** គូស្នេហ៍ទាំងពីរ
គ្រប់ទីរកផ្លូវ ដោះស្រាយបញ្ហា
គ្រួសារតម្រូវ រឿងរ៉ាវអាស្រូវ
រត់ទៅឃ្លាតឃ្លា ។

១៨៧ - សំបុកឥតបា អំរែកគ្រួសារ
ទុក្ខាកំព្រា ដោតជ័យសិក្សា
ស្នេហាត្រាំត្រា គូព្រេងជួបគ្នា
ចិត្តជា នារី ៗ

និពន្ធដោយ សាម សុនិត
ទូរសព្ទ ០៧៧ ២៣ ៩០ ២៣
០៩៦ ៧៦៩ ១១ ៧៧
០៩៧ ៧៣០ ៧៧ ០៨

ចិត្តជានារី